**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**សាលាក្រុងភ្នំពេញ**
**លេខ :** ៤១៩ សហវ.

ភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០២

# ប្រកាស

## របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និងសាលាក្រុងភ្នំពេញ
## ស្តីពី
## ការលុបចោលកិច្ចសន្យាជួលអតីតទីតាំងរោងភាពយន្តខេមរៈ

✻✻✻✻✻✻✻✻✻✻

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យលេខ នស/រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩

-បានឃើញអនុក្រឹត្យលេខ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែមករាឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៩/១៩១ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

-យោងកិច្ចសន្យាបន្ថែមចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៣ លើកិច្ចសន្យាស្តីពីការជួលអតីតទីតាំងរោងភាពយន្តខេមរៈ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩២

-យោងលិខិតលេខ ៦៥០ សហវ.ទរ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**<u>សំរេច</u> :**

**ប្រការ១ :** លុបចោលកិច្ចសន្យាស្តីពីការជួលអតីតទីតាំងរោងភាពយន្តខេមរៈ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩២ និងដកហូតអតីតទីតាំងរោងភាពយន្តខេមរៈដែលមានអាស័យដ្ឋានស្ថិតនៅតាមដងវិថី ហ្សាលដឺហ្គោល ក្នុងសង្កាត់ អូរឬស្សីទី៤ ខ័ណ្ឌ៧មករា ពីលោក យ៉ាន់ ទានយ៉ាន់ ដោយមូលហេតុមិនគោរពតាមកិច្ចសន្យា ។

**ប្រការ២** : លោក យ៉ាន់ ទានយ៉ាន់ ត្រូវទូទាត់បំណុលថ្លៃឈ្នួលអតីតទីតាំងរោងភាពយន្តខេមរៈ ត្រឹមខែមីនា ឆ្នាំ២០០២ ដែលមានទឹកប្រាក់សរុបចំនួន ៣៣.០០០$ (សាមសិបបីពាន់) ដុល្លារអាមេរិក និងប្រាក់ពិន័យចំនួន ៨.២៥០$ (ប្រាំបីពាន់ពីរយហាសិប) ដុល្លារអាមេរិកជូនរដ្ឋក្នុងរយៈពេល ៣០ថ្ងៃ ជាកំហិត គិតចាប់ពីថ្ងៃដែលបានចេញប្រកាសលុបចោលកិច្ចសន្យា និងដកហូតអតីតទីតាំងរោងភាពយន្តខេមរៈ ជាផ្លូវការ ។

**ប្រការ៣** : កិច្ចសន្យាស្តីពីការជួលអតីតទីតាំងរោងភាពយន្តខេមរៈ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩២ និង លិខិតបទដ្ឋានដទៃទៀត ដែលមានការពាក់ព័ន្ធនឹងការជួល និង ប្រគល់អតីតទីតាំងរោងភាពយន្តខេមរៈត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** : នាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ការិយាល័យវិនិយោគរាជធានីភ្នំពេញ និង លោក យ៉ាន់ ទានយ៉ាន់ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ៥** : ប្រកាសអន្តរក្រសួង ស្តាប័ននេះមានប្រសិទ្ធិភាពអនុវត្តជាគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០២

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

គាត ឈន់

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានប្រតិបត្តិការ)
- សាលាខ័ណ្ឌ៧មករា
- ដូចប្រការ០៤ (ដើម្បីអនុវត្ត)
- ឯកសារ

pwsplxt/Prakas on contract termination of ... (eR)